# តើអ្វីទៅហៅថា កាបំប្លែងជាកូដ ឬការចាក់សោទិន្នន័យដើម្បីការពារពីការប្រើប្រាស់ដោយគ្មានសិទ្ធិអនុញ្ញាត?

## ហើយតើអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទកុមារ ប្រើប្រាស់វាយ៉ាងដូចម្តេច?

## តើវាដំណើរការយ៉ាងដូចម្តេច?

ការបំប្លែងទិន្នន័យជាកូដដើម្បីការពារពីការប្រើ ដោយគ្មានសិទ្ធិអនុញ្ញាត គឺជាមធ្យោបាយនៃការក្លែង ឬការលាក់បាំងសារ ឬអត្ថបទដោយអនុវត្តតាមជំហ៊ានបន្តបន្ទាប់នៃ [:កម្មវិធីកុំព្យូទ័រដែលបំប្លែងទិន្នន័យជាកូដ] ដូច្នេះបើសារអត្ថបទធ្លាក់ទៅក្នុង 'ដៃ ជនដទៃ (ដែលជាអ្នកមិនត្រូវទទួល) នោះ' បុគ្គលដែលមើល ឬអានសារនោះ នឹងមិនអាចយល់អំពីអ្វីៗដែលសរសេរឡើយ។ ឧទាហរណ៍វានឹងផ្លាស់ប្តូរសារដូចជា "ខ្ញុំនឹងជួបអ្នកនៅថ្ងៃច័ន្ទ" ទៅជាសារដែលបំប្លែងជាកូដ "p98hUls#yeb!"




សារ ដែលមិនអាចយល់បាននេះ - ជាសារកូដ - ដែលបន្ទាប់មកត្រូវបានបញ្ជូនតាមអ៊ីនធឺណិតទៅអ្នកទទួល។ បុគ្គលដែលទទួលសារ នេះត្រូវមាន 'លេខ ឬអក្សរសម្ងាត់សម្រាប់ដោះកូដ' ដែលអ្នកដទៃ មិន ដឹង ហើយលេខ ឬអក្សរសម្ងាត់នេះត្រូវផ្តល់ជូនទៅអ្នកទទួលដោយអ្នកផ្ញើសារ ដើម្បីដោះកូដ ឬទទួលបាន នូវសារដើមមកវិញ។ ដំណើរការនេះហៅថាការដោះកូដ (Decryption)។ បើគ្មានលេខ ឬអក្សរសម្ងាត់ ទេ សារ ឬរូបភាពនេះគឺមិនអាចអានបាន ឬមើលឃើញនោះឡើយ។

### ការបំប្លែងទិន្នន័យជាកូដត្រូវបានប្រើប្រាស់ដើម្បីការពារ:



ទិន្នន័យ (ឧទាហរណ៍៖ ឯកសារ រូបភាព កុំព្យូទ័រ) ឬការធ្វើចរាចរណ៍សាច់ប្រាក់តាមអ៊ីនធឺណិត (ឧទាហរណ៍៖ ធនាគារ) លេខសម្ងាត់ បណ្តាញ កុំព្យូទ័រ និងសារអេឡិចត្រូនិច។

ដំណើរការបំប្លែងទិន្នន័យជាកូដ/ការដោះកូដ មានដូចខាងក្រោម*:




* សូមកត់សម្គាល់ថា នេះជាឧទាហរណ៍មួយ ហើយនៅមានវិធីផ្សេងទៀតដើម្បីបម្លែងកូដ និងដោះកូដទិន្នន័យចេញ

## ការបំប្លែងកូដទិន្នន័យត្រូវបានប្រើប្រាស់ដោយអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទកុមារ

អ្នកប្រព្រឹត្តបទល្មើសផ្លូវភេទកុមារ ទាក់ទងគ្នាទៅវិញទៅមកលើបណ្តាញអ៊ីនធឺណិតដោយប្រើវិធីសាស្រ្តជាច្រើន ដើម្បីលាក់អត្តសញ្ញាណ និងការប្រព្រឹត្តិរបស់ពួកគេពីអាជ្ញាធរនានា។

ឧទាហរណ៍៖ អ្នកប្រព្រឹត្តបទល្មើស បំប្លែងកូដទិន្នន័យ ស្តីពីការរំលោភបំពានផ្លូវភេទកុមារ ដូច្នេះមនុស្ស ឬអង្គភាពដែលមិនទទួលបានការអនុញ្ញាតមិនអាចដឹងថាវាជាសម្ភារៈអាសអាភាសកុមារឡើយ។ ឬក៏អ្នកប្រព្រឹត្តិបទល្មើសអាចបំប្លែងកូដកុំព្យូទ័រ ឬហាតឌីសដើម្បីបង្ការមិនឲ្យ អាជ្ញាធរនានារកឃើញភស្តុតាងនៃបទល្មើស នៅក្នុងអំឡុងពេលនៃការឆែកឆេរផ្ទះរបស់ពួកគេនោះឡើយ។

បន្ថែមលើនេះ ការបំប្លែងកូដទិន្នន័យអនុញ្ញាតឲ្យអ្នកប្រព្រឹត្តបទល្មើសបញ្ជាក់អត្តសញ្ញាណ អ្នកដែលពួកគេកំពុងទាក់ទងលើបណ្តាញអ៊ីនធឺណិត។

កម្មវិធីបំប្លែងកូដទិន្នន័យខ្សោយខ្លះ អាចត្រូវបានបំបែកដោយកុំព្យូទ័រដែលមានសមត្ថភាពខ្ពស់ ប៉ុន្តែជាគោលបំណង គឺ៖ ជាទូទៅ មានកម្មវិធីបំប្លែងកូដទិន្នន័យដែលមានសមត្ថភាពខ្លាំងជាច្រើន មិនអាចបំបែក ដោយគ្មានលេខ ឬអក្សរសម្ងាត់សម្រាប់ដោះកូដនោះឡើយ។

ការបំប្លែងកូដទិន្នន័យ រួមចំណែកធ្វើឲ្យមានភាពស្មុគ្រស្មាញបន្ថែមចំពោះការស៊ើបអង្កេតរបស់មន្ត្រីអនុវត្តច្បាប់។

តារាងព័ត៌មាននេះផលិតដោយអង្គការ ECPAT អន្តរជាតិ។ ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងការផលិតដោយអង្គការ UNICEF។